ឧ-តាម

# វេយ្យាករណ៍ ដោយរូបភាព

សំរាប់ឧត្តមដ្ឋាន




B-6
D-42
ភ.34

ឌុ.គាម

# វេយ្យាករណ៍

ដោយរូបភាព

សំរាប់ឧត្តមដ្ឋាន

## វេយ្យាករណ៍, អក្ខរាវិរុទ្ធ-វាក្យសព្ទ

សំនួរ និង រូបភាព

ការផ្សាយរបស់

បណ្ណាគារសេង-ង៉ួន ហួត

រក្សាសិទ្ធិ

ព.ស. ២.៥០០

គ.ស. ១៩៥៧

ARCHIVES NATIONALES
RÉGIE DU DÉPOT LÉGAL

ARCHIVES NATIONALES
B.64.648

# អារម្ភកថា

ដោយខ្ញុំ មានគោលបំណងតែមួយ ដែលចង់ឲ្យក្បួនវេយ្យាករណ៍ខ្មែរសម្បូរ ហើយឲ្យមានរបៀបរៀបរយងាយរៀនដូចវេយ្យាករណ៍នៃភាសាបរទេស នឹងឲ្យមានគោលខណ្ឌតាមលំដាប់ថ្នាក់ ទើបខ្ញុំយកវេយ្យាករណ៍ បរភាសាខ្លះ ភាសាបាលីខ្លះ ភាសាសំស្ក្រឹតខ្លះ មកប្រៀបធៀបមកតម្រូវតាមក្បួនវេយ្យាករណ៍ខ្មែរ ហើយខ្ញុំឲ្យឈ្មោះថា **វេយ្យាករណ៍ដោយរូបភាព** សំរាប់ឧត្តមដ្ឋាន ។

ក្នុងវេយ្យាករណ៍នេះដែលវិចិត្រដោយរូបភាព ក៏ខ្ញុំតម្រូវទៅតាមមេរៀនមួយ ៗ ដោយហោចទៅគ្រាន់តែមើលរូបក៏ចូលចិត្តដែរ ។

ហេតុនេះខ្ញុំសូមអង្វរចិត្ត លោកអ្នកដែលឈ្លាសវៃក្នុងវេយ្យាករណ៍ខ្មែរ សូមជួយថែវេយ្យាករណ៍យើងឲ្យបាន

ស្រួលរៀនឡើង ដើម្បីឲ្យអក្សរសាស្ត្រយើងចំរើនរុងរឿងក្នុង
សាកលលោក ។

ឌុ-គាម

សិស្សសាណៈបាលីជាន់ខ្ពស់

សិស្សវិទ្យាល័យស៊ីសុវត្ថិ

# វេយ្យាករណ៍

វេយ្យាករណ៍ គឺជាក្បួនសំរាប់បង្រៀននូវអក្ខរវិធី ដើម្បីឲ្យសរសេរ និយាយឲ្យបានត្រឹមត្រូវក្នុងភាសាខ្មែរ ។

## អក្ខរវិធី



កុមារមុនី ហាត់អានតែ ៦ ខែ ក៏អាចមើលសារ-ពត៌មានបាន សៀវភៅ ទស្សនាវដ្ដី បានស្ទាត់ ៗ

### ពិនិត្យ

កុមារមុនី ដែលអាចអានទស្សនាវដ្ដីបាន សារពត៌មានបាន សៀវភៅបាន អាស្រ័យតែខ្មែរយើងមានវេយ្យាករណ៍

ដែលមានអក្ខរវិធីត្រឹមត្រូវ ហើយភាសាខ្មែរយើងមិនមែន ជាភាសាស្ទាប់ ៗ បានជាខ្ញុំហ៊ានពោលថា ភាសាខ្មែរ ជាភាសាមិនស្ទាប់នោះ ពីព្រោះភាសាខ្មែរយើងអាចសរ-សេរទៅមិនចេះអស់មិនចេះហើយសរសេរដូចម្ដេចក៏បាន ៗ ការដែលសរសេរពោលចេះតែបានអាស្រ័យតែអក្ខរវិធីដែល មានស្រៈសុទ្ធ ១៥ តួ ស្រៈនិស្ស័យ ២០ និងព្យញ្ជនៈ ៣៣ តួ ៗ

## មេរៀន

អក្ខរវិធីក្នុងភាសាខ្មែរបែកជាពីរយ៉ាងគឺ ស្រៈនិងព្យញ្ជនៈ

១- ស្រៈ បែកជា ២ យ៉ាងគឺ ស្រៈសុទ្ធឬ ស្រៈពេញតួ និងស្រៈនិស្ស័យ

ក) ស្រៈសុទ្ធឬស្រៈពេញតួ មាន ១៥ តួគឺ

អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ

ឧ. អារម្មណ៍ ឦសាន, ឧទ្ទាម ... ឱកាស ...

ខ) ស្រៈនិស្ស័យ មាន ២០ តួគឺ

## -មេរៀន (គ)-

-ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ
ៅ ុំ ំ ាំ ះ ៗ

ចំណាំ ស្រៈនិស្ស័យនេះ ចំពោះស្រៈ "អ" ជាស្រៈមានសំឡេងតែឥតរូប ព្រោះតែកាលណាសរសេរផ្សំទៅស្រៈ "អ" នៅកប់បាត់នឹងតួព្យញ្ជនៈ ព្រោះហេតុនេះបានជាថាមានតែ ២០ តួ ។

២-ព្យញ្ជនៈ មាន ៣៣ តួគឺ:

ក្កខ្ខគ្គឃ្ឃង្ង ច្ចឆ្ឆជ្ជឈ្ឈញ្ញ ដ្ដឋ្ឋឌ្ឌឍ្ឍណ្ណ ត្តថ្ថទ្ទធ្ធន្ន ប្បផ្ផ
ព្ពភ្ភម្ម យ្យរ្រល្លវ្វស្សហ្ហឡអ្អ ។

ព្យញ្ជនៈទាំង ៣៣ តួនេះ បែកជាពួកមាន ២ យ៉ាងគឺវគ្គ ១ នឹងសេសវគ្គ ឬអវគ្គ ១

ក) វគ្គ បែកជា៥វគ្គ ក្នុងវគ្គនិមួយៗ មាន៥តួគឺ

វគ្គទី ១ ក្ក ខ្ខ គ្គ ឃ្ឃ ង្ង

## -មេរៀន (ត)-

វគ្គទី ២ ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ

វគ្គទី៣ ដ្ដ ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ

វគ្គទី ៤ ត្ត ថ្ថ ទ្ទ ធ្ធ ន្ន

វគ្គទី ៥ ប្ប ផ្ផ ព្ព ភ្ភ ម្ម

ខ) សេសវគ្គ ឬ អវគ្គ មាន ៨ តួ

យ្យ រ្រ ល្ល វ្វ ស្ស ហ្ហ ឡ អ

ចំណាំ: បានជាឲ្យឈ្មោះថាជាសេសវគ្គ ពីព្រោះអក្សរ ទាំង ៨ តួនេះមានឋានៈទីកើតមិនដូចគ្នា ។

ឃោសៈនិងអឃោសៈ

៣ ព្យញ្ជនៈទាំង ៣៣ តួនេះ មានសំឡេងជាពីរពួកគឺ ឃោសៈនិងអឃោសៈ

ក) ឃោសៈ ព្យញ្ជនៈដែលមានសំឡេងធំគ្រលរ មាន អក្សរទី ៣ ទី ៤ នឹងចុងវគ្គ ហើយនឹងអក្សរសេសវគ្គ៦

## -មេរៀន (ត)-

គឺ គឃង ជឈញ ឌឍណ ទធន ពភម យរលវហឡ

២) អឃោសៈ ព្យញ្ជនៈដែលមានសំឡេងតូចស្រលួប មិនតឹកកង មានអក្សរដើមវគ្គ ២ តួ និងអក្សរស គឺ

ក ខ ច ឆ ដ ឋ ត ថ ប ផ ស

ចំណាំ ក្នុងភាសាបាលី ហ ឡ មិនមែនជាអឃោសៈឡើយ តែអ្នកវេយ្យាករណ៍តែងប្រទាំថា ជាអក្សរអឃោសៈដែរ ៗ

### សិថិលធនិត

៤. សិថិល គឺព្យញ្ជនៈដែលមានសំឡេងមួយធូរស្រាល ឥតមានអក្សរផ្សំ គឺ ក គ ច ជ ដ ឌ ត ទ ប ព

ឧ. ក្តាម...គោ...ចចក...ចោរ...ដែក...ត្រឹមត្រូវ...បាន...

៥- ធនិត គឺព្យញ្ជនៈដែលមានសំឡេងតឹង មានអក្សរឯទៀតផ្សំ ទើបបានកើតជាសំឡេងឡើងគឺ

## - មេរៀន (គ) -

| | |
|---|---|
| ក + ហ > ខ | ឌ + ហ > ឍ |
| គ + ហ > ឃ | ត + ហ > ថ |
| ច + ហ > ឆ | ទ + ហ > ធ |
| ជ + ហ > ឈ | ប + ហ > ផ |
| ដ + ហ > ឋ | ព + ហ > ភ |

អក្សរវគ្គទទឹងវគ្គនៅពោលតែឯងគឺ ង ញ ណ ន ម យ រ ល វ ស ហ ឡ

វេយ្យាករណ៍ ភិក្សុសត្ថ

សំនួរ

១- ដើម្បីនឹងនិយាយសរសេរឲ្យបានត្រឹមត្រូវ តើយើងរៀនអ្វីជាមុន? ភាសាយើងបានជាឈ្មោះថា ភាសារស់ តើអាស្រ័យដោយមានអ្វី?

២- ស្រៈមានប៉ុន្មានយ៉ាង? ស្រៈសុទ្ធមានអំណាចដូច

ម្ដេច ? ស្រៈនិស្ស័យមានអំណាចដូចម្ដេច ? ចូរលើកឧទាហរណ៍ ?

៣- ព្យញ្ជនៈប៉ុន្មានតួដែលជាអឃោសៈ ? ប៉ុន្មានតួជាឃោសៈ ? យរលវសហឡ ម្ដេចបានជាគេមិនរាប់យកធ្វើជាមួយវគ្គទៅទៀត ?

៤- សិថិលនិងធនិតប្លែកគ្នាដូចម្ដេច ? ព្យញ្ជនៈណាខ្លះដែលមិនរាប់ថាជាសិថិលនិងធនិត ?

ការហាត់

៥. ចូរតែងឃ្លាយ៉ាងខ្លីឲ្យមានអក្សរសុទ្ធតែជាសិថិល ? មួយឃ្លាទៀតសុទ្ធតែជាឃោសៈ ? ដូចឧទាហរណ៍នេះ

សិថិលៈ ក្របី ពញទូក

ឃោសៈ ឈ្មួញនេះ ដួញគោមាឌធំ ១

មេរៀន (គ)

## ព្យញ្ជនៈបន្ថែម

៦. ព្យញ្ជនៈបន្ថែមត្រូវប្រើត្រីសព្ទ ( ៊ ) និងមូសិកទន្ត ( ៉ ) ។

ក) អក្សរឃោសៈ ថែមមូសិកទន្តទៅជាអឃោសៈគឺ

ង > ង៉; ញ > ញ៉; ប > ប៉; ម > ម៉; យ > យ៉; រ > រ៉; វ > វ៉ ។

ចំណាំ ប្ដូរតែអក្សរ ប ជាអក្សរ អឃោសៈ ដល់ថែមមូសិកទន្តមកក៏នៅតែអឃោសៈដដែល

ខ) អក្សរអឃោសៈ ដាក់ត្រីសព្ទទៅជាឃោសៈ គឺ ប > ប៊; ស > ស៊; ហ > ហ៊; អ > អ៊;

បានជាមានអក្សរបន្ថែមមកទៀត ពីព្រោះប្រើមិនគ្រប់គ្រាន់ៗ ភាសាខ្មែរជាភាសាសម្បូរទៅដោយពាក្យ ហេតុនេះត្រូវតែបន្ថែមព្យញ្ជនៈមកទៀត កុំឲ្យខ្វះក្នុងការសរសេរនិយាយ ។

វេយ្យាករណ៍. វាក្យសព្ទ

សំនួរ

៦– ព្យញ្ជនៈបន្តមត្រូវប្រើវណ្ណយុត្តិណាខ្លះ ? វណ្ណយុត្តិមូសិកទន្តសំរាប់ដាក់លើអក្សរណា ? ឲ្យទៅជាព្យញ្ជនៈដូចម្ដេច ?

# មេរៀនទី២

## ព្យាង្គ




កុមារពីរនាក់នេះ កំពុងអារពាក្យឲ្យដាច់ពីគ្នា ៗ

ឯកុមារពីរនាក់ទៀត កំពុងផ្សំអក្សរឲ្យបានជាពាក្យមួយ

### ពិនិត្យ

ពាក្យមួយ ៗ គេអាចកាត់ចេញជាព្យាង្គ ៗ ព្យាង្គមួយគឺការផ្សំព្យញ្ជនៈស្រៈ ដែលគេអាចថាបានជាពាក្យ

មួយម៉ាត់ ឧទាហរណ៍ ដូចជាកេ្មងតាំងពីរនាក់នេះ ខំតម្រៀបផ្សំព្យញ្ជនៈស្រៈ ដើម្បីឲ្យបានជាពាក្យមួយគឺ ឃោសនាការ ៗ ពាក្យថា ឃោ ១ម៉ាត់ ស ១ម៉ាត់ នា ១ម៉ាត់ ការ ១ម៉ាត់ រួមបានជាព្យាង្គមួយ ៗ

មេរៀន

១—ព្យាង្គ គឺជាសង្កាត់នៃពាក្យមួយ ដែលគេអាចនិយាយឲ្យមានសូរដាច់ពីគ្នា

ឧ. ឃោសនាការ មេអំបៅ

២— ព្យាង្គមាន ២ យ៉ាងគឺ ព្យាង្គរាយ និងព្យាង្គតម្រួត

ក) ព្យាង្គរាយ គឺព្យាង្គដែលសរសេរគ្មានជើងជើង

ឧ. ឃោសនាការ អំពិលអំពែក

ខ) ព្យាង្គតម្រួត គឺព្យាង្គដែលសរសេរមានជើងជើង ឧ. បច្ចាមិត្រ កល្យាណមិត្ត

ព្យាង្គតាំងពីរនេះ បែកទៅជា ៤ ទៀតគឺ

- មេរៀន (ត) -

ក) ឯកព្យាង្គ ឧ. គោ, ឆ្កែ

ខ) ទ្វិព្យាង្គ ឧ. អំពៅ ក្មេងក្មាង

គ) ត្រីព្យាង្គ ឧ. កុមារី ឯកឧត្តម

ឃ) ពហុព្យាង្គ ឧ. មហាសាគរ រដ្ឋមន្ត្រីធម្មការ

វេយ្យាករណ៍ ពាក្យសព្ទ

សំនួរ

៧- ដូចម្ដេចដែលហៅថាព្យាង្គ? ពាក្យដែលជាប់គ្នាជាពីរម៉ាត់ហៅថា ព្យាង្គអ្វី? ព្យាង្គដែលលើសពីបីទៅហៅថាព្យាង្គអ្វី? ចូររកឧទាហរណ៍?

ការហាត់

៨- ចូរគូសបន្ទាត់បញ្ឈរនៅចំកណ្ដាលព្យាង្គមួយ ១ ឲ្យដាច់ពីគ្នាដូចមានឧទាហរណ៍ខាងក្រោមនេះនឹងពាក្យ ទាំងឡាយនេះហើយឲ្យឈ្មោះ ឧ. អំពៅ (ទ្វិព្យាង្គ)

អំពិលអំពែក។ វិទ្យាល័យស៊ីសុវត្ថិ។ អនុវិទ្យាល័យនារី។ សាលាបឋមសិក្សាកុមារី។ មហាវិថី។ ក្រសួងតុលាការ ។ល។

៩. ចូររកស័ព្ទមួយមុខៗ ឲ្យបាន ៥ ពាក្យគឺ

ក) នាមដែលមាន ៥ ព្យាង្គ ឲ្យបាន ៥ ពាក្យ

ខ) គុណនាមដែលមាន ២ ព្យាង្គ ឲ្យបាន៥ពាក្យ

គ) កិរិយាសព្ទ អំពីកូនសិស្ស ដែលកំពុងធ្វើករណីយកិច្ចដែលមាន ២ ព្យាង្គ

១.អត្ថបទ វត្តខ្ញុំណ្ណលោម

វត្តឧណ្ណាលោម ជាអារាមធំមួយក្នុងក្រុងភ្នំពេញ មានចេតិយបូរាណធំមួយ ប្រតិស្ឋាននៅខាងក្រោយ។ ព្រោះថាគារមានចេតិយធំបន្ទាប់គ្នា ៥ ទៀតព័ទ្ធជុំវិញ ។ល។

តាមសេចក្ដីដំណាលតាមកថានៅក្នុងចេតិយនេះគេបញ្ចុះឧណ្ណាលោមគឺរោមប្រជុំចិញ្ចើមនៃមហាថេរមួយរូប

មានគោត្តនាម បកតំនាមមិនប្រាកដ ។ លុះដល់មក

កន្នុងភាគនៃសតវត្សរ៍ទី ២៥ នៃពុទ្ធសករាជ (ព.ស.

២៤២៣) សម្តេចព្រះមហាសង្ឃរាជព្រះនាម ទៀន បាន

បញ្ចុះព្រះបរមសារីរិកធាតុនៃព្រះសក្យមុនីសម្មាសម្ពុទ្ធ ជា

មកុដកន្នុងត្រៃលោកមួយអង្គតូច កន្នុងចេតិយធំមធ្យមភាគ ។

(ជា - ទន់)

១០. ចូរស្រង់យកគុណនាម ដែលមានពាក្យគ្នុកន្នុង

អត្ថបទនេះ ? ហើយនិងពហុព្យាគ្នុ ?

១១. ចូរពន្យល់ពាក្យ អង្គតូច ជាបទគុណទៅនឹង

ពាក្យណា ? តើគុណនាម "អង្គតូច" នេះ អាចរៀនទៅ

ដូចម្តេចបានទៀត ?

១២. អក្ខរាវិរុទ្ធិ បរម (ម.ជ ប៉ុម មាក់) ។

១៣. សរសេរតាមសូត្រ វិត្ថុឧណ្ណាលោម

## ១៤. តែងសេចក្ដី

ចូរអ្នកនិយាយរៀបរាប់អំពីបូជនិយវត្ថុណាមួយ ដែលអ្នកបានដឹងច្បាស់ ៗ តើបូជនិយវត្ថុនោះគេប្រតិស្ឋានឡើងដើម្បីអ្វី (បញ្ចុះអដ្ឋិធាតុ ឬ មួយទុកគ្រាន់ជាអនុស្សាវរីយ៍)

---

## មេរៀនទី ៣

### សទិសស័ព្ទ (សំឡេងដូចគ្នា) — វេវចនស័ព្ទ (សេចក្ដីដូចគ្នា)



១– ឆ្មាឈ្មោលលោតរំលងអម្បោះ ឆ្មារ មួយសរសៃ

២– ឆ្មាជា សត្រូវ នឹង កណ្ដុរ សត្វទាំងពីរនេះជា បច្ចាមិត្រ នឹងគ្នាយូរណាស់ហើយ

### ពិនិត្យ

១– ពាក្យពីរម៉ាត់ដែលមានសំឡេងដូចគ្នាគឺ ឆ្មា នឹង ឆ្មារ ប៉ុន្តែពាក្យទាំងពីរនេះ គ្រាន់តែមានសំឡេងដូចគ្នាប៉ុណ្ណោះទេ ឯន័យសេចក្ដីនឹងអក្ខរាវិរុទ្ធខុសគ្នា ដូច្នេះពាក្យពីរនេះ ឆ្មា នឹង ឆ្មារ ហៅថា សទិសស័ព្ទ

លេខកូដ : ..........................
ចុះបញ្ជី

២- ពាក្យពីរម៉ាត់ទៀតដែលមានអត្ថន័យប្រហែលគ្នា គឺ សត្រូវ នឹង បច្ចាមិត្រ ៗ ពិតមែនតែពាក្យនេះមានសំឡេងខុសគ្នា អក្ខរាវិរុទ្ធខុសគ្នា តែអត្ថន័យដូចគ្នា ដូច្នេះ ពាក្យពីរនេះគឺសត្រូវនឹងបច្ចាមិត្រ ហៅថា វេវចនសព្ទ ។

## មេរៀន

១-សទិសសព្ទ គឺពាក្យដែលមានសូរសំឡេងដូចគ្នា តែអត្ថន័យនឹងអក្ខរាវិរុទ្ធផ្សេងគ្នា

១. តាម្នាក់ក្អាត់ដើរធ្លាក់ទៅក្នុងជ្រោះចោត គាត់ចោទថាខ្ញុំច្រានគាត់, ខាងចោទក៏ ចោទបែបនេះ គឺចោទដោយកំហឹង (សុង-ស៊ីវ)

២-វេវចនសព្ទ គឺពាក្យដែលមានអត្ថន័យដូចគ្នា សូរសំឡេងនឹងអក្ខរាវិរុទ្ធផ្សេងគ្នា ៗ

១. វិជ្ជាជាទ្រព្យដ៏ប្រសើរខ្ពង់ខ្ពស់ឧត្តុង្គឧត្តម បានមក

អំពីការសន្សំសិក្សារៀនសូត្រ ទំស្វាញព្យាយ ។

(ឌ. គ.)

វេយ្យាករណ៍ ពាក្យសព្ទ

១៥– ចូរតែងឃ្លាខ្លីៗ នឹងពាក្យសទិសសព្ទខាងក្រោមនេះ ក្ដ៏, កែ, គេ, គេហ៍

១៦– ចូររកវេវចនសព្ទ នឹង ពាក្យខាងក្រោមនេះ ប្រសើរ, ឧឡារិក, ទុក្ខ, លំបាក, ទូលាយ

សំគួរ

១៧– សទិសសព្ទនឹងវេវចនសព្ទមានន័យខុសគ្នាដូចម្ដេចខ្លះ ? ពាក្យសទិសសព្ទផ្សេងគ្នាត្រង់ណា ? ដូចគ្នាត្រង់ណា ?

អត្ថបទ ឈាបនកិច្ច

បើមានជនណាមួយ ទទួលអនិច្ចកម្ម គេត្រូវនិមន្តព្រះសង្ឃមកឲ្យពរទឹកដល់បុគ្គលនោះ ។ កាលលើកសពចំអាសទឹករួចហើយគេរុំសពនឹងសំពត់ស្លប់ ជួនកាលគេបង់ប្រាក់

កាក់ ឬ ចិញ្ចៀន ១ វង់ទៅក្នុងមាត់ ។ គេដាក់ខ្មោចទៅក្នុងក្តារមឈូសរួចគេនិមន្តព្រះសង្ឃបង្សុកូល ។

ដល់ថ្ងៃហែសពចេញពីផ្ទះ គេនិមន្តព្រះសង្ឃបង្សុកូលម្តងទៀត គេហៅថា បង្សុកូលរំកិលសព ។ លុះហែសពទៅដល់ទីប៉ាឆា គេនិមន្តលោកសង្ឃបង្សុកូលម្តងទៀត មុននឹងរំលាយសព ។

ភ្ញុកទាំង ៤ នាក់ស្លៀកសំពត់ស ប៉ុនប្រុសបំផុតខ្មោចណាស់ ។ ទំនៀមនេះមានរហូតដល់មកសព្វថ្ងៃនេះ ។ កាលបើឆេះសុះហើយ គេលត់ភ្លើងរើសធាតុដាក់ក្នុងកោដ្ឋយកទៅបញ្ចុះទុកក្នុងចេតិយឯវត្តអារាម ។

(ឌ. ត.)

សំនួរ

១៩– ចូររកសទិសស័ព្ទនឹងវេវចនស័ព្ទ ដែលមានក្នុងអត្ថបទនេះ ? ចូរតែងឃ្លានឹងពាក្យ កោត, កោដិ, កោដ្ឋ ?

ចូររកវេវចនស័ព្ទនឹងពាក្យប្រុសប់ ?

២០- អក្ខរាវិរុទ្ធ

ពរ (ន.) មានរ ។ សព (ន.) បា-ឆវ ឆ>ស វ>ព ជាសព សរសេរមានព ។ ក្តារ (រ) ។ ហៃ (គ្មានរ) ។

២១- សរសេរតាមសូត្រ ឈាបនកិច្ច

២២- តែងសេចក្តី

អ្នកបានឃើញគេហែសពនៅតាមផ្លូវ ចូរអ្នកអធិប្បាយអំពីក្បួនហែ តើអ្នកចាប់អារម្មណ៍ត្រង់ណាខ្លះ ដែលគួរធ្វើឲ្យអ្នកសង្វេគ? (ស្លៀកស - កោរក្បាល - យំ - ទួញ - សោក)

# មេរៀនទី ៤

## អត្ថានុរូប

## អត្ថបដិរូប





១. ផ្លែល្ហុង ខ្ចី មានរសមិនឆ្ងាញ់

២-ផ្លែល្ហុង ទុំ មានរសផ្អែម

៣- ក្មេង ខ្ចី សំដីមិនដឹងខុសត្រូវ

៤ចាស់ទុំស្លូតគេឈមជាទីពឹង

## ពិនិត្យ

ពាក្យ ខ្ចី - ទុំ ដែលមានរូបធៀបខាងលើនេះមានន័យខុសគ្នា ព្រោះហេតុនោះពាក្យទាំងពីរនេះមានន័យតាមសេចក្តី

អត្ថានុរូប គឺសេចក្ដីដែល មានន័យ តាមធម្មជាតិ តាមកំណើតដើមមកមិនមានសេចក្ដីប្រៀបធៀប គឺមានន័យចំ ។

១. ផ្លែចេកខ្ចី ផ្លែក្រូចទុំ

អត្ថបដិរូប គឺពាក្យដែល មានន័យដោយសេចក្ដីប្រៀបធៀបមិនមែនចេញមក តាមធម្មជាតិ ។ ពាក្យនេះច្រើនតែនៅក្នុងកាព្យឃ្លោង ។

១. សំដីនៅខ្ចីទេ! បុប្ផាមិនគួរ អាសូរដល់កន្ទន់ផង

(ប្រលោមលោក)

## មេរៀន

នាម កិរិយាស័ព្ទ គុណនាម មានន័យជាអត្ថានុរូប ទាំងអត្ថបដិរូប ។

អត្ថានុរូប ពាក្យដែលមានអត្ថន័យតាមធម្មជាតិ កំណើតមក គ្មានសេចក្ដីប្រៀបធៀប ។

១. ផ្លែស្វាយខ្ចីមានរសជូរ

អត្ថបដិរូប ពាក្យដែលមានសេចក្តីប្រៀបធៀប

ខ. ក្មេងនៅខ្ចីសំដីមិនសូវដឹងខុសត្រូវ

វេយ្យាករណ៍ វាក្យសព្ទ

សំនួរ

២៣. ពាក្យដូចម្តេចដែលហៅថា អត្ថានុរូប? ដូចម្តេចដែលហៅថា អត្ថបដិរូប? ពាក្យដែលជា អត្ថបដិរូបគេច្រើនប្រើក្នុងទីដូចម្តេច?

២៤- ចូររកពាក្យជា អត្ថានុរូប ធៀបទៅជាអត្ថបដិរូប ឲ្យបានចំនួន ៥ ដូចឧទាហរណ៍ខាងក្រោមនេះ

១. អត្ថានុរូប ថ្ងៃរសៀល

អត្ថបដិរូប អាយុប៉ុណ្ណេះល្មមរសៀលហើយ

២៥- ចូរតែងឃ្លានឹងពាក្យខាងក្រោមនេះ ជាអត្ថានុរូប នឹង អត្ថបដិរូប រសៀល-ផ្អែម-ជូរ-ចត់-ដើរ

អត្ថបទ ជីតាខ្ញុំ

ជីតាខ្ញុំ មានអាយុជាង ៧០ ឆ្នាំហើយ ។ គាត់លែង

ទៅធ្វើការឯស្រែទៀតហើយ ៗ គាត់នៅតែផ្ទះជួយកិច្ចការក្នុងផ្ទះសម្បែងមានមើលចៅបន្តិចបន្តួចជាដើម ៗ ដល់ថ្ងៃសីលគាត់អញ្ជើញទៅវត្ត ដដែកជមិអាចជាមួយចាស់ទុំដូចៗគ្នា ៗ ពេលយប់គាត់ឲ្យឱវាទដល់កូនចៅដែលនៅក្មេងខ្ចី សេចក្ដីប្រាជ្ញាទន់ខ្សោយឲ្យខំរកស៊ីរៀនសូត្រ កាន់ខ្លួននៅវ័យក្មេង កុំឲ្យធ្វើដូចគាត់ដែលឈប់ចង់បានចង់មានហើយនោះ ៗ

គាត់មានអាយុចំណាស់ប៉ុណ្ណោះទៅហើយនោះ គេថាគាត់រសៀលទៅហើយ គិតខំតែពីស្វែងរកធម៌ទុកជាស្បៀងដើម្បីធ្វើដំណើរទៅបរលោក ៗ ព្រោះហេតុនោះរាល់តែថ្ងៃខ្ញុំឃើញគាត់នៅមុខរូបបដិមាករ នមស្ការរំលឹកពុទ្ធគុណធម្មគុណ និងសង្ឃគុណ ៗ

(ឧ. កាមមុនី)

សំនួរ

២៦– ចូរស្រង់យកពាក្យដែលជាអត្តបដិរូបកនិងអត្តបទ

នេះ? ហើយពន្យល់ន័យនៃពាក្យនោះ? តាមអត្ថានុរូបមន្ត

រូបតាមអត្ថបដិរូបមន្ត?

២៧– ចូរពន្យល់ពាក្យ? ឧបាទ, វ័យ, បរលោក,

បដិមាករ

ការហាត់

២៨– ចូរពន្យល់អត្ថន័យនៃពាក្យខាងក្រោមនេះ?

ក្របទ្វី, សំដីទ្វី, នៅទ្វី, ទ្វីលុយ, មិនទ្វី

២៩– អក្ខរាវិរុទ្ធ

ធមិៈ (មិ) មានសូរដូចប្រកបនឹងរ ។ អាចិ (ចិ)

មានសូរដូចរដែរ ។ បរលោក ម.ថ. បៈរៈលោក ម្យ៉ាង

ទៀតថា ប–ឡោក ។

សរសេរតាមសូត្រ ជីតាខ្ញុំ

៣១ - តែងសេចក្ដី - ។

នៅក្នុងគ្រួសាររបស់អ្នក អ្នកមានជីតាមួយមិនខានទ ។

ចូរអ្នកអធិប្បាយអំពីអាកប្បកិរិយារបស់គាត់ បរិយាទនឹងការ

ងាររបស់គាត់ៗ តើអ្នកអាចទាញបទប្រៀបធៀបបានទាំង

ឲ្យអ្នកដូចម្ដេចខ្លះ?

លោកភាសិត

ក្របីស៊ីស្រូវទើបធ្វើរបង
ពេលរៀបប្រឡងទើបស្វាធ្យាយ
ពេលចេញដំណើររៀបវេចសំពាយ
ទាំងបីអន្តរាយអសារបង់ៗ

# មេរៀនទី ៨

## សន្តានពាក្យ




### ពិនិត្យ

១–សន្តានពាក្យនេះជាពាក្យដែលមានអំបូរចេញពីធាតុដើម មកជាមួយគ្នា ជួនកាលពាក្យដើមជាកិរិយាស័ព្ទ សន្តានពាក្យទៅជាកិរិយាដូចគ្នា ឧ. ហើរ (កិ.) ចង្ហើរ (កិ.)។ ជួនកាលនាមទៅជានាមដដែល ឧ. ជំនួញ (ន.) ឈ្មួញ។ ជួនកាលគុណនាម ទៅជានាម ឧ. ក្ដៅ (គុ) កំដៅ (ន.)

ៗ ល ៗ គុន៏កាសាបាលីមានធាតុដើមល្អណាស់ ដូចជា

ការ (ករ-ធាតុ) កិច្ច (ករ-ធាតុ) ករណីយ (ករធាតុ)

កម្ម (ករ-ធាតុ).,.. ដូរេចះជាដើម ។

-មេរៀន-

សន្ធានពាក្យ គឺជាពាក្យដែលមានអំបូរជាមួយគ្នា

១. ជួញ (កិ) ឈ្មួញ (ន.) ដំណួញ (ន.)

ចំណាំ: សន្ធានពាក្យនេះ កាលបើក្លាយទៅជាពាក្យមួយទៀតហើយ

គេអាចហៅថា កិតនាម ឬកិរិយាក្រិតបាន ។

ក)- នាមក្រិត ឬកិតនាម នាមដែលក្លាយចេញមក

ពីស័ព្ទដើមជាគុណនាម ជាកិរិយាស័ព្ទ

១- កាច (គុ) កំណាច (ក្រិ-ន-)

ដើរ (កិ.) ដំណើរ (ក្រិ-ន-)

## មេរៀន (ឆ)

១)- កិរិយាក្រិតឬកិតកិរិយា គឺកិរិយាដែលក្លាយមកពីស័ព្ទជាកិរិយាក្តី ជានាមក្តី ជាគុណនាមក្តី

ឧ- ដើរ (កិ) បណ្ដើរ (កិ.ក្រិ)

ឈ្មួញ (ន.) ជួញ (កិ.ក្រិ)

ខូច (គុ) បង្ខូច (កិ.ក្រិ)

វេយ្យាករណ៍ វាក្យស័ព្ទ

សំនួរ

៣២- ដូចម្ដេចដែលហៅជាសន្ទានពាក្យ? សន្ទានពាក្យដែលចេញទៅជានាមក្រិត និងក្រិតកិរិយា តើមានស័ព្ទដើមជាបទអ្វី? ចូរធ្វើពាក្យខាងក្រោមនេះឲ្យទៅជានាមក្រិត

អរ. ល្អ. ស្រឡាញ់. ឈាន ដេក. ស.

អត្ថបទ **សេចក្ដីក្រោធនាំឲ្យខាត**

មានពពែពីរតួ ដើរមកទល់ជួបគ្នានៅកណ្ដាលស្ពាន ។

ពពែមួយថា ស្ពាននេះដើរបានតែតួមួយ ៗ ទឹងដើរបៀសគ្នាពុំបាន បើដូច្នេះត្រូវតែអ្នកឯងថយទៅក្រោយសិន ចាំយើងដើរទៅដល់ចុងស្ពានកាលណា សឹមអ្នកឯងដើរមកចុះ ៗ ពពែមួយទៀតពោលថា បើឯងមានការប្រញាប់បន្ទាន់ ត្រូវតែអ្នកឯងថយទៅខាងក្រោយសិន ចាំយើងដើរទៅដល់ចុងស្ពានកាលណា សឹមអ្នកឯងដើរទៅចុះ ពពែទាំងពីរសឹងពុំព្រមថយក្រោយដូចគ្នា កាន់មានះរៀងខ្លួន ក៏បោលសំរុកជល់គ្នាញ្រុទៅញ្រុមក ដោយកំលាំងទោសោមោហោបាំងបិទឥតប្រាជ្ញាទឹងសម្របគ្នា ៗ ពពែទាំងពីរជល់គ្នាធ្លាក់ទៅក្នុងទឹកទាំងពីរតួ បានក្តីវេទនាដោយធ្លាក់ទឹកមានអាការផ្សេង ៗ ៗ

មាស- រឿង (បរិយាសាស្ត្រ)

សំនួរ

៣៣— ចូរអ្នកធ្វើកិរិយាក្នុងអត្ថបទនេះ ឲ្យទៅជានាមក្រិត? សត្វពពែទាំងពីរតួនេះ ធ្លាក់ទឹកមកពីហេតុអ្វី?

អត្ថបទទាំងមូលនេះ អ្នកអាចពោលប្រដូច ភាសិតខ្លីណា មួយឬទេ ?

អ្នកនិពន្ធរឿងនេះឈ្មោះអ្វី ?

៣៤ - អក្ខរាវិរុទ្ធ

ក្រោធ (ធ) ៗ តោ សោ មោ ហោ (គ្មានរះជាវចនៈ សំរាប់ប្រាប់ឯកវចនបាលី) ៗ

៣៥ - សរសេរតាមសូត្រ សេចក្តីក្រោធនាំឲ្យខាត

៣៦ - តែងសេចក្តី

ចូរអ្នកតែងអំពីមនុស្សពីរទទឹងគ្នា រៀបរាប់អំពីហេតុដែលឈ្លោះគ្នា និងសេចក្តីដែលជេរគ្នាទៅវិញទៅមក ៗ នៅទីបំផុតមានអ្នកដទៃទៀតទៅរំលត់ជំលោះនោះ ៗ

មេចបានតែមិនធ្វើទៅ

មុននឹងគេធ្វើ

គ្រីស្តូហ្វកូឡុម

## មេរៀនទី ៦

# ឆ្មា



កុមារ មុនី អង្គុយរៀននៅលើតុ មានចិត្តជាប់តែក្នុងមេទន្ទេញ នៅក្បែរនោះ ឆ្មាកំពុងតែលបចាប់កណ្ដុរ ៗ

---

### ពិនិត្យ

១- នាមសំរាប់សំដែងប្រាប់នូវឈ្មោះ មនុស្ស សត្វ,

វត្ថុគ្រប់យ៉ាង ដូចជាកុមារ បិតា ឆ្មា កណ្ដុរ ត្រី សុទ្ធតែជា

នាម ។

៤- នាមទាំងអស់នោះ ខ្លះជា សាធារណនាម

ខ្លះជា អសាធារណនាម ខ្លះជា រូបិនាម, អរូបិ

នាម, សមាសនាម, ពហុនាម . . .

ម. សាធារណនាម . . . កុមារ, ឆ្មា

អសាធារណនាម . . . មុនី

រូបីនាម . . . ត្រី

អរូបីនាម . . . បិត្ត

ពហុនាម . . . ហ្វូង, ពួក

សមាសនាម . . . មនុស្សទេវតា

## សព្ទ

| | | |
|---|---|---|
| កុមារ | សាធារណនាម | នាមមនុស្ស |
| មុនី | អសាធារណនាម | |
| តុ | សាធារណនាម | នាមវត្ថុ |
| កណ្ដុរ | សាធារណនាម | នាមសត្វ |

## មេរៀន

នាម គឺសព្ទសម្រាប់សំដែងនូវឈ្មោះ,មនុស្ស សត្វ វត្ថុទាំងអស់ ។

ឧ. កុមារ, ឆ្មា, តុ . . .

នាមចែកជា ២ យ៉ាងគឺ សាធារណនាម, អសាធារណនាម ។

១- សាធារណនាម គឺនាមដែលសំដែងនូវឈ្មោះមនុស្ស សត្វ វត្ថុ ទូទៅមិនចំពោះ ។

ឧ. មនុស្ស, ឆ្មា, តុ

## មេរៀន (ត)

២- អសាធារណនាម គឺនាមដែលសំដែងនូវឈ្មោះមនុស្សតែមួយ សត្វតែមួយ វត្ថុតែមួយ មិនទូទៅ

ឧ. មុន៏, អាដួង, ភ្នំពេញ ។

សាធារណនាមចែកជា ៤ គឺ

ក) បកតិនាម នាមដែលកើតឡើងតាមធម្មតា មិនកើតចេញមកពីពាក្យឯទៀត

ឧ. ទឹក, ដី, ខ្យល់, មេឃ . . .

ខ) នាមក្រិត នាមឯណា ដែលក្លាយចេញមកពីវត្ថុដើមដែលជានាមក្តី គុណនាមក្តី កិរិយាក្តី

ឧ. ដំណើរ (ន.) > ដ្ហើរ (ន.កិ.)

ទិញ (កិ.) > ទំនិញ (ន.កិ.)

កាច (គុ.) > កំណាច (ន.កិ.)

ពាក្យដែលជានាមក្រិតកើតឡើងដោយអញ្ញសត្តព្យញ្ជនៈ

## មេរៀន(គ)

គ) សមាសនាម គឺនាមដែលកើតឡើងដោយផ្សំពាក្យ ២ ម៉ាត់ ឬច្រើនម៉ាត់

ឧ. ដំរលុប ក្រដាសផ្ទិត . . .

នាមនេះ ជួនកាលកើតឡើងដោយនាមនិងនាម ជួនកាលនាមនិងកិរិយា ជួនកាលគុណនាមនិងនាម

ឧ. ផ្ទះ (ន.) + ថ្ម (ន.) > ផ្ទះថ្ម (ស.ន.)

ព្រះអង្គ (ន.) + ខ្ពង់ (គុ.) > ព្រះអង្គខ្ពង់(ស.ន.)

សៀវភៅ (ន.) + មើល (កិ.) > សៀវភៅ-មើល (ស,ន.)

បើកងកាសាបាលី សំស្រ្កឹតវិញគេប្រើដោយតបទសន្ធិ ឬបទសមាស

ឧ. វិទ្យាល័យស៊ីសុវត្ថិ អនុវិទ្យាល័យនារី

## មេរៀន (គ)

ឃ) តទ្ធិតនាម គឺនាមដែលក្លាយចេញពីកិរិយាសព្ទ គុណនាមនិងនាម មកជានាម

ឧ. អ្នកលេង, អ្នកវិទ្យាសាស្ត្រ, អ្នកតូច . . .

ក្នុងតទ្ធិតនាមនេះត្រូវប្រើពាក្យថា អ្នក នៅមុខពាក្យដែលទៅជាតទ្ធិតនាមនោះ ។

វេយ្យាករណ៍ ពាក្យសព្ទ

សំនួរ

៣៧- ពាក្យដូចម្ដេចដែលហៅថានាម ? មានប៉ុន្មាន? គឺអ្វីខ្លះ? អសាធារណនាមប្រើដូចម្ដេច? សាធារណនាមបែកជាប៉ុន្មានទៅទៀត? ចូរលើកឧទាហរណ៍ជាអរូបនាម?

ការហាត់

៣៨- ចូរធ្វើគុណនាមនិងកិរិយាខាងក្រោមនេះ ឲ្យទៅជានាមក្រិត ៖

ឈើ, ធ្ងន់, ដេក, សង់, ខ្ពស់, លួច, ចារ, ការ,

៣៩. ចូរតែងឃ្លាជាមួយនឹងនាមក្រិត ខាងក្រោម

ថ្មើរ, ខ្នារ, បំណារ, រណារ, សំណាង, លំអ

អត្ថបទ លានិងឆ្កែ

នៅនគរពារាណសី មានអ្នកជ្រលក់ម្នាក់ឈ្មោះក
បដកៈ ។ បុរសនោះ រស់តែត្រេកត្រអាលសប្បាយ
ភរិយាស្រស់ប្រិមប្រិយ ក៏ដេកលក់ទៅ ។ ពេលនោះ
ចូលលួចទ្រព្យសម្បត្តិ សត្វលាប្រាប់អាពាលថា ហៃ
ឡាញ់ ហេតុអ្វីអ្នកលួចចូលមកលួច អ្នកមិនព្រុស?
ម្ចាស់ដឹង នែបងលា កុំចេះដឹងជាងយើង យើងក
នេះចាំងយប់ចាំងថ្ងៃ ឃើញថាបានសុខយូរណាស់មកហើ
តែម្ចាស់គ្មានឲ្យអាហារបន្តិចបន្តួចជាអំណោយសោះ ។

លាជេរសុនខថា “ស្តាប់មើលពាក្យៈ អាពាលបង្រ”
ឆ្កែឆ្លើយថា “ បើជនណាហៅគេខ្ញុំបំរើ តែពេលមានអា
ជននោះ ហៅថាម្ចាស់ដូចម្ដេចកើត?

លំដាប់នោះ លាក្រោកឈ្ងាំងដេរថា "នែអាចព្រៃ អាគំនិតខូច ឯងគង់ដឹងទេ ចាំតែម្ចាស់ក្រោកអញមុខជាប្រាប់មិនខាន ទើបលាស្រែកអស់ទំហឹងទាល់តែម្ចាស់ភ្ញាក់ស្ទុន ស្ទាក្រញាងឡើងពីដំណេក ចាប់ដំបងសំពងលាស្ទើរតែក្សិណក្ស័យទៅ ។

សំនួរ

៤០-ចូរស្រង់ពាក្យដែលជាអសាធារណនាម ដែលមានក្នុងអត្ថបទនេះ ? និងពាក្យនាមក្រិត ?

៤១-ចូរធ្វើកិរិយាសព្ទក្នុងអត្ថបទនេះ ឲ្យទៅជានាមក្រិត ដូចជាឧទាហរណ៍ ដេក > ដំណេក

៤២-ក្នុងអត្ថបទនេះ អ្នកគួរយកគតិបានដូចម្តេចខ្លះ ? សំដីរបស់សុនខដែលពោលនោះ តើត្រូវឬខុស ? តើម្ចាស់ដែលសំពងលាដូច្នេះ ដោយហេតុអ្វី ?

៤៣-អក្ខរាវិរុទ្ធ

ដោរ (រ) ៗ អញ ជាអញ្ញត្រស័ព្ទមិនឲ្យសរសេរមាន បន្តក់ (់) ឡើយ បើតាមសូរ ត្រូវតែសរសេរជាអាញ់ ៗ

៤៤-សរសេរតាមសូត្រ លាងឹងដែ្ក

៤៥-តែងសេចក្តី

អ្នកបានចិញ្ចឹមសត្វពាហនៈ បណ្តាសត្វពាហនៈទាំងនេះ អ្នកចូលចិត្តសត្វណាជាងគេ ព្រោះហេតុអ្វី ចូរពាញប្រយោជន៍ដែលបានមកពីសត្វពាហនៈនោះ ៗ

# មេរៀនទី ៧

## លិង្គ

### លិង្គរបស់នាម

| បុំលិង្គ | ឥត្ថីលិង្គ | នបុំសកលិង្គ |
| --- | --- | --- |
|  |  | X |
| ១ លោកគ្រូកំពុងតែបង្រៀនកុមារ | ២ . អ្នកគ្រូកំពុងតែបង្រៀនកុមារី | ៣ ឡើយ |

## ពិនិត្យ

១ លោកគ្រូ ជាភេទប្រុស មានលក្ខណៈភិនភាគ គួរឲ្យសំគាល់បានប្លែកពីភេទឯទៀត កំពុងតែបង្រៀន

ពន្យល់មេរៀនដល់ពួកកុមារ ដែលជាភេទដូចគ្នា ពាក្យថា កុមារ លោកគ្រូ នេះហើយដែលលោកថាជា. បុំលិង្គ

២.អ្នកគ្រូ ជាភេទស្រី ដែលមានលំនាំឫកពាលក្ខណៈប្លែកពីប្រុស ហើយអាចសំគាល់ថាជាស្ត្រីបាន កំពុងតែបង្រៀនកុមារី ដែលមានភេទដូចគ្នា ពាក្យថា កុមារី អ្នកគ្រូ ជាឥត្ថីលិង្គ

៣.ភេទដែលមិនមែនប្រុសឬស្រី ឈ្មោលញីជា. ភេទខ្ទើយ ហៅថា នបុំសកលិង្គ ។

សម្ពន្ធលិង្គ

| | |
|---|---|
| លោកគ្រូ | នាមសាធារណៈ បុំលិង្គប្រធានរបស់បង្រៀន |
| កុមារ | នាមសាធារណៈ បុំលិង្គកម្មរងបង្រៀន |
| អ្នកគ្រូ | នាមសាធារណៈ ឥត្ថីលិង្គប្រធានបង្រៀន |
| កុមារី | នាមសាធារណៈ ឥត្ថីលិង្គកម្មរងបង្រៀន |
| ខ្ទើយ | នាមសាធារណៈ នបុំសក.បិង្គ លិង្គត្ថៈ |

បំណាំ: របៀបសម្ពន្ធនាមត្រូវពិនិត្យមើលមុខងារដូច្នេះគឺនាម មានមុខងារជាប្រធាន·កម្ម (កម្មបែកទៅជាច្រើន· ទៀត)

មេរៀន

ភេទរបស់នាមហៅថាលិង្គ ។ លិង្គមាន ៣ យ៉ាងគឺ បុំលិង្គ, ឥត្ថីលិង្គ និងនបុំសកលិង្គ ។

១. បុំលិង្គ ភេទសំគាល់ភេទមនុស្សប្រុស សត្វ, វត្ថុឈ្មោល ។

ឧ. កសិករ ឪពុក, មាន់ឈ្មោល . . .

២. ឥត្ថីលិង្គ ភេទសំគាល់ភេទមនុស្សស្រី សត្វ, វត្ថុញី ។

## មេរៀន (ត)

ឧ.ម្ដាយមីង មេមាន់

៣ នបុំសកលិង្គ ភេទនៃមនុស្ស សត្វវត្ថុ ដែលមិនមែនជា បុំលិង្គ ឬឥត្ថីលិង្គ

ឧ.មនុស្សខ្ទើយ

លិង្គទាំង ៣ នេះ បើចែកឲ្យខ្វីទៅទៀតមាន ២ យ៉ាងគឺជាតិលិង្គ និងសម្មតិលិង្គ

ក) ជាតិលិង្គ គឺលិង្គដែលកំណត់ដោយ ភេទ.ប្រុស.ស្រី ឬខ្ទើយ តាមកំណើតដើមភេទពិតៗ

ឧ.ប្រុស.ស្រី. មាន់..

ខ) សម្មតិលិង្គ គឺលិង្គដែលគេគ្រាន់តែបញ្ញត្តសន្មតឲ្យហៅ ខុសពីទំនងដើមកំណើត

ឧ.ប្ដី, ប្រពន្ធ. ស្វាមី..

បំណាំ នបុំសកលិង្គពិបាកចំណាំណាស់ព្រោះពី·

## មេរៀន(ត)

មនុស្សពេញប៉ុន្តែនាមនេះមិនសូវជួបប្រទះ ។

៤–តាមពាក្យបាលីឬសំស្ក្រឹតទាំងឡាយដែលប្រើជាពាក្យខ្មែរ តែងតែមានលិង្គទាំងអស់ហើយ ហើយអាចសំគាល់បានដោយងាយផង ។

ឧ សាមណេរ (បុំ) សាមណេរី (ឥ) វត្ថុ (នបុំ)

បើតាមភាសាខ្មែរសុទ្ធវិញ គ្មានគ្រឿងសំគាល់ឲ្យជ្រះស្រឡះថាជាបុំលិង្គ ឥត្ថីលិង្គ នបុំសកលិង្គទេ តែគេអាចចំណាំដោយសារពាក្យដូចខាងក្រោមនេះ

| បុំលិង្គ | ឥត្ថីលិង្គ | នបុំសកលិង្គ |
|---|---|---|
| ប្រុស, ឈ្មោល | ស្រី, ញី, មេ | |
| អា, បា, កម្លោះ | មី, មីកា, ក្រមុំ | ខ្ទើយ |
| តា, ពូ, មា, ឪពុក | យាយ, ដូន, មីង, ម៉ែ | |

នៅមានពាក្យដទៃទៀត ដែលបែកចេញមកឲ្យដឹងថាជាលិង្គនេះលិង្គនោះបាន ។

វេយ្យាករណ៍ ភក្យស័ព្ទ

សំនួរ

៤៦. លិង្គមានអត្ថន័យដូចម្ដេច? មានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ? ដូចម្ដេចដែលហៅថាសមតិលិង្គ? ជាតិលិង្គ? ពាក្យខ្មែរមានសព្ទណាខ្លះដែលអាចប្រាប់ឲ្យដឹងថាជានបុំ-សកលិង្គ?

ការហាត់

៤៧. ចូររកនាមមនុស្សជាបុំលិង្គឲ្យបានចំនួន ១០ ហើយធ្វើឃ្លាខ្លីៗ នឹងពាក្យទាំងនោះដូចឧទាហរណ៍ខាងក្រោមនេះ

៤ - កសិករធ្វើការតាំងពីព្រឹកទល់ព្រលប់គ្មានឈប់ឈរៗ

អត្ថបទ ក្រុមញាតិខ្ញុំ

ក្រុមញាតិរបស់ខ្ញុំ មិនសូវមានជនច្រើនទេ ។ ជនដែលមានអាយុច្រើនជាងគេគឺ ជីដូនជីតាខ្ញុំ ។ មាតាបិតា

ជាមេបន្ទុកក្នុងគ្រួសារ ។ បងស្រីខ្ញុំ អាចជួយសំរាល បន្ទុកម្ដាយខ្ញុំខ្លះដែរ ឯប្អូនស្រីវិញ នៅវ័យក្មេង ទៅរៀន សាលាបឋុមកជា ជាមួយនឹងកុមារ-ទារិកាជាជីដូនមួយ ។ ចំណែកបងប្រុស. យកប្រពន្ធទៅរកស៊ីចិញ្ចឹមជីវិតជាមួយ ម្ដាយក្មេក ដែលជាស្ត្រីមេម៉ាយ ។ ម្ដាយក្មេកបងខ្ញុំ ស្រឡាញ់បងខ្ញុំជាកូនប្រសាណាស់ ថែមទាំងត្រូវជាជនទ្វង នឹងម្ដាយឪពុកខ្ញុំទៀតផង ។ ខ្ញុំនឹងបងប្អូនប្រុសស្រីរបស់ បងប្រុសខ្ញុំក៏ម្ដាយក្មេកស្រឡាញ់រាប់អានដូចបងខ្ញុំដែរ ។

ជនដែលនៅជាមួយខ្ញុំនោះ មិនមែនត្រឹមតែប៉ុណ្ណោះ ទេ នៅមានកម្មករកម្មការិនីទៀត ដែលមានមុខការធ្វើ រៀងខ្លួន អ្នកខ្លះទៅឃ្វាលមេគោ ដែលមានអាលុកដូន ទៅផង ៗ សុនខនេះដឹងណាស់មិនសូវនឿយដល់ម្ចាស់ ទេ វាអាចគៀង មេបា-កូនសត្វពាហនៈបានៗ ការ

ជួបជុំក្រុមញាតិ ជាការរស់ដោយប្រសើរ ។

សំនួរ

៤៨-ចូរស្រង់យកនាមមនុស្សដែលមាននៅក្នុងអត្ថបទនេះ? ហើយចង្អុលបង្ហាញគ្រប់លិង្គ? .(ដូច ឪពុក បុំ ជាដើម)

ការហាត់

៤៩-ចូរចំបែកនាមជាឥត្ថីលិង្គទាំងនេះទៅជាបុំលិង្គជាមួយពាក្យខាងក្រោមនេះ

កុមារី, ទារិកា, មេម៉ាយ, មេ

៥០-ចូររកនាមមនុស្សដែលជាបុំលិង្គ ហើយជាភាសាបាលីឲ្យបានចំនួន១០ ដូចឧទាហរណ៍- សមាជិក· ភិក្ខុ. .

៥១-ម្ដាយឪពុកក្មេករបស់បងប្រុស ស្រីយើងត្រូវជាដូចម្ដេចនឹងម្ដាយឪពុកយើង? មនុស្សស្រីគ្មានប្ដីគេហៅថាដូចម្ដេច? មនុស្សប្រុសគ្មានប្រពន្ធគេហៅថាដូចម្ដេចទៅវិញ?

៥២-អក្ខរាវិរុទ្ធ

ប្រពន្ធ (ន្ធ) ។ គ្រួសារ (មានរ) ។ ប្រសា (គ្មានរ)
សុខ ១ (ប្រកបទី ១ ជាភាសាបាលី)

៥៣-សរសេរតាមសូត្រ ក្រុមញាតិខ្ញុំ

៥៤-តែងសេចក្តី

ចូរអ្នកអធិប្បាយអំពីកិច្ចការដែលជនម្នាក់ៗ ធ្វើនៅវេលាយប់ពេលដែលនៅជួបជុំគ្នា តើអ្នកគួរចាប់អារម្មណ៍នៅជនណាជាងគេ ព្រោះហេតុអ្វី?

# មេរៀនទី ៨

## វចនៈ

### វចនៈរបស់នាម

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
|  |  |
| ១– កុមារម្នាក់នេះអង្អែល ឆ្មាឈ្មោលមួយ ដោយ សេចក្ដីស្រឡាញ់ | ២– កុមារទាំងឡាយអង្អែល ឆ្មាឈ្មោលបី ដោយសេចក្ដី ពេញចិត្ត |

## ពិនិត្យ

១– ពាក្យថា ម្នាក់, មួយ ក្នុងប្រយោគខាងឆ្វេងជាពាក្យសំ

រាប់ប្រាប់ចំនួនរបស់អ្វីតែមួយ តែម្នាក់មិនច្រើន ហៅថា

# ឯកវចនៈ :

២- ប្រយោគខាងស្តាំខាងលើ ពាក្យថាទាំងឡាយ បី ជាពាក្យសំរាប់សំគាល់ឲ្យដឹងចំនួន ច្រើនលើសពី២ទៅហៅថា

# ពហុវចនៈ

---

## សម្ពន្ធ

| | |
|---|---|
| ម្នាក់ | បទវិសេសនៈរបស់កុមារ បុំ. ឯកវចនៈ |
| មួយ | បទវិសេសនៈរបស់ឆ្មាឈ្មោលបុំ. ឯកវចនៈ |
| ទាំងឡាយ | បទវិសេសនៈរបស់កុមារបុំ. ពហុវចនៈ |
| បី | បទវិសេសនៈរបស់ឆ្មាឈ្មោលបុំ. ពហុវចនៈ |

ចំណាំ: វចនៈទាំង ២ ត្រូវមានលិង្គដូចជានាមដែរ ព្រោះហេតុនោះត្រូវជាបទគុណរបស់នាមជាដរាប ដែលត្រូវសម្ពន្ធបួល ។

## មេរៀន

វចនៈ ពាក្យសំគាល់ប្រាប់ចំនួននាមមនុស្ស សត្វ វត្ថុ ។

វចនៈ ចែកជា ២ យ៉ាង គឺ ឯកវចនៈ នឹង ពហុវចនៈ

១- ឯកវចនៈ ពាក្យដែលដំណាងចំនួនមនុស្ស សត្វវត្ថុតែមួយ

ឧ- មនុស្សម្នាក់, ក្អែកមួយ, ក្តារមួយបន្ទះ....

២- ពហុវចនៈ ពាក្យសំគាល់ប្រាប់ចំនួននាមមនុស្ស សត្វនឹងវត្ថុ គប់តាំងពី ២ ឡើងទៅ ។

ឧ- មនុស្សពីរនាក់, ក្អែកបី, ខ្វក់មួយគូ.....

ចំណាំ: ពាក្យខ្មែរដែលសំគាល់ឲ្យដឹងថាឯកវចនៈពហុវចនៈ មានដូចតទៅនេះ

## មេរៀន (៩)

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ម្នាក់, មួយ, ម្ខាង, គោល . . . | ទាំងឡាយ, ទាំងអស់, ទាំងពួង, ច្រើន, ភ្លោះ, ៗ បី, បួន. . . |

នៅមានពាក្យជាច្រើនទៀតដែលអាចចំណាំនូវវចនៈបានៗ នាមដែលអាចឲ្យស្គាល់បានថាជា ឯកវចនៈ ពហុវចនៈ បាននោះ ត្រូវភ្ជាប់ពាក្យក្នុងតារាងខាងលើទៅជាមួយនឹងនាមដែលត្រូវប្រកប ។

១. ភិក្ខុមួយរូប . . .

ឯក្នុងភាសាបាលី សំស្ក្រឹតវិញវចនៈរបស់ពាក្យនោះ ត្រូវសំគាល់ទៅតាមវិភត្តិ ដែលនៅចុងស័ព្ទមួយៗ

១. កុមារ (ឯ.) កុមារា (ពហុ.) ព្រឹក្ស (ឯ.) ព្រឹក្សា (ពហុ.)

វេយ្យាករណ៍ វាក្យស័ព្ទ

សំនួរ

៥៥– វចនៈរបស់នាមមានអត្ថន័យដូចម្ដេច ? មានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ? ក្នុងភាសាបាលីសំស្ក្រឹតគេសំគាល់វចនៈដូចភាសាខ្មែរឬទេ ? គេសំគាល់ដោយអ្វី ?

ការហាត់

៥៦– ចូរធ្វើពាក្យជាពហុវចនៈ ឲ្យទៅជាឯកវចនៈ ដូចមានខាងក្រោមនេះ៖ ព្រឹក្សា, កុមារ, មនុស្ស, បុរសពីរនាក់ សុនខ៥, កិច្ចទាំងឡាយ , គ្រូទាំងពួង

អត្ថបទ ការប្រឹងប្រែងអាចញុំាងប្រយោជន៍ឲ្យសំរេច

ក្នុងរដូវវិស្សា មានអ្នកបររទេះម្នាក់ ដឹកទ្រព្យពេញទៅដួញស្រុកក្រៅ លុះបររទេះទៅបានពាក់កណ្ដាលផ្លូវ កង់រទេះផុងកប់នៅក្នុងភក់ជាប់នឹងថ្កល់ ៗ គាត់ខំប្រហារគោទាំងទ្វេអស់ទំហឹង ក៏មិនអាចធ្វើរទេះនោះឲ្យកំរើកបាន

ឡើយ ៗ បុរសនោះអស់សង្ឃឹម អង្គុយនៅក្រោមព្រឹក្សា ស្រែកអំពាវនាវឲ្យទេវតាយមយក្ស ព្រះនារាយណ៍ជួយ ៗ

ព្រះនារាយណ៍ដ៏មានបុណ្យឮសំរែកនោះហើយក៏មកជួយ ហើយពោលទៅបុរសនោះថា „ នែអាក្ខើ អាចំកួត ហេតុអ្វីក៏ពេញចិត្តតែបន់ស្រន់ពឹងកំលាំងឲ្យគេជួយមិនគិតរកកំលាំងខ្លួនឯង បើអ្នកចង់ឲ្យយើងជួយ អ្នកក្រោកឡើង វាយគោទាំងអស់ ខ្ញុំនឹងជួយបាន ៗ

អ្នកបររទេះឮដូច្នោះ ក៏ខំវាយគោទាំងឡាយ ហើយច្រានកង់តែម្នាក់ឯងយ៉ាងពេញទំហឹង ដោយទឹកសង្ឃឹមថាគេនឹងជួយ រទេះក៏រួចរបូតពីផុកទៅបានដោយស្រួល គ្មានទុបស័គ្គអ្វីទៀតឡើយ ៗ

( ឧ ជាមមុនី )

សំនួរ

៤៧- ចូរស្រង់យកនាមដែលជាឯកវចនៈនិងពហុវចនៈ ? ពាក្យបាលីណាខ្លះដែលជាពហុវចនៈ ? ហើយចូរធ្វើ

ពាក្យនោះឲ្យទៅជាឯកវចនៈទៅវិញ?

៥៧- ចូររកសទ្ទានពាក្យនឹង សំរែក,ជួយ

៥៩- អក្ខរាវិរុទ្ធ

យក្ស (ក្ស.ក្ខ) ។ ព្រះនាកយណ៌ (ណ៌) ។ កំហឹង គ្មានត្រីស័ព្ទ (៊) ពីព្រោះព្យញ្ជនៈដើមជាឃោសការេហាដែលមានសំឡេងត្រលួចឲ្យទៅជាត្រលរបាន គឺហ ២ ហ៊ តែមិនឲ្យមានត្រីស័ព្ទជាដាច់ខាត) ។

៦០= អត្ថាធិប្បាយនៃអត្ថបទ

ផ្នែកនៃអត្ថបទ បានគតិដល់មនុស្ស ដែលគ្មានវិរិយភាពដេកចាំតែផ្សងសំណាង ពឹងកំលាំងគេ ដូចមានឃ្លាបញ្ជាក់ឲ្យឃើញថា „ ហេតុអ្នកពេញចិត្តតែបន់ស្រន់ពឹងកំលាំងឲ្យគេជួយ មិនគិតរកកំលាំងខ្លួនឯង " ។

៦១- សរសេរតាមសូត្រ សេចក្តីប្រឹងប្រែងអាចញុំាងប្រយោជន៍ឲ្យសំរេច

៦២- តែងសេចក្តី

អ្នកបានធ្វើករណីយកិច្ចណាមួយដែលអ្នកស្មានថាធ្វើមិនបានមិនហើយ តែដោយអ្នកមានវីរិយភាព ករណីយកិច្ចនោះក៏ហើយបានសំរេច ចូរអ្នកនិយាយអំពីលទ្ធផលដែលកើតមកពីសេចក្តីព្យាយាម ។

## មេរៀនទី៩

# គុណនាម

### បទគុណរបស់នាម



មុនីនឹងទៅសាលារៀន កុមារមុនីជាកូនសុភាព តែងតែគោរពមាតាបិតាដ៏មានចិត្តសប្បុរស ជារាល់ថ្ងៃៗ

ពិនិត្យ

ពាក្យដែលសំរាប់បញ្ជាក់លក្ខណៈ គំនិតកិរិយាមារយាទ របស់នាមនាម ដូចពាក្យថាសុភាព ជាសំដីសំដែងចរិយា របស់មុនី ថាជាកូនមានសណ្ដាប់ធ្នាប់ មានចរិយាសាស្ត្រៗ

សប្បុរសប្រាប់លក្ខណៈ ចិត្តនៃមាតាបិតារបស់មុនី ថា ជាអ្នកសន្តោស ។ ពាក្យថាសុភាព សប្បុរសនេះ ហៅថា គុណនាម

### សម្ពន្ធ

| | |
|---|---|
| សុភាព | គុណនាម បុំលិង្គឯកវចនៈ បទវិសេសន, របស់កូន |
| សប្បុរស | គុណនាម នបុំសកលិង្គឯកវចនៈ បទវិសេសនៈ របស់ចិត្ត |

បំណាំ: គុណនាមទាំងអស់ត្រូវសម្ពន្ធបួលទៅជាមួយនឹងនាម ព្រោះជាបទវិសេសនៈ ហើយត្រូវមានលិង្គវចនៈ ដូចនាមដែលត្រូវសម្ពន្ធបួល ។

ចិត្តសព្ទៈ តាមភាសាបាលីថាជា នបុំសកលិង្គ ។

ហេតុនេះបានជាសម្ពន្ធថា នបុំសកលិង្គ ។

### មេរៀន

គុណនាម គឺជាពាក្យសំរាប់សំដែងនូវលក្ខណរបស់នាម

ឧ. មនុស្សចាស់ខ្លះ ពុំមានធ្មេញទេ តែចូលចិត្តបរិភោគគ្រឿងស្ងួត ដូចសាច់គោជាដើម(ច-ឈ្មុំ)

## មេរៀន(គ)

គុណនាមចែកជា ៣ យ៉ាងគឺ បកតិគុណនាម, វិសេស-គុណនាមនិងអតិវិសេសគុណនាម ។

ក- បកតិគុណនាម= គុណនាមដែលសំដែងលក្ខណៈរបស់នាមតាម លំអានប្រក្រតី, តាមធម្មតា-

១. សត្វគោចូលចិត្តទីស្ងាត់... ហេតុនេះដែលនឹងថែទាំចិញ្ចឹមគោឲ្យបានធំធាត់បំរើន គេត្រូវធ្វើក្រោលវាទៅទីខ្ពស់ស្ងួតមិនមានកក់ផុង(មា.ស–វៀន)

ខ) វិសេសគុណនាម គុណនាមដែលសំដែងលក្ខណៈរបស់នាមឲ្យប្លែកជាងបកតិគុណនាម

១. នៅនានាប្រទេស គេនិយមរាប់អាន ការអានសៀវភៅសំខាន់ ជាង ការមើលកុន មើលល្ខោនច្រើនណាស់

(ប.ឈុំ)

គ) អតិវិសេសគុណនាម គុណនាមសំដែង

## មេរៀន (ត)

លក្ខណៈរបស់នាមពិសេសបំផុតឲ្យប្លែកបំផុតទៅទៀត ។

១. រាជអាណាខេត្ត របស់ព្រះបាទអសោកមហារាជនោះ ធំទូលាយ សំបើមណាស់ ជិតគ្រប់អស់ដែនស៊ណ្ឌៀ ទាំងមូល (ញ.ថែម)

បំណាំ;វិសេសគុណនាម នឹងអតិវិសេសគុណនាម ត្រូវមានពាក្យបន្ថែមនៅខាងចុងគុណនាមទៀត ទើបប្លែកពីបកតិគុណនាមដូចតារាងខាងក្រោមនេះ

| បកតិគុណនាម | វិសេសគុណនាម | អតិវិសេសគុណនាម |
|---|---|---|
| គុណនាមនៅធម្មតា | ជាង. លើស<br>ប្លែក<br>វិសេស . . .<br>(នៅចុងគុណនាម) | បំផុត, ណាស់,<br>យក់,ក្រៀស,ស្គុស,<br>បណ្ដាច់, បំឡែក,<br>(នៅចុងគុណនាម) |

វេយ្យាករណ៍ វាក្យសព្ទ

សំនួរ

៦៣- ដូចម្ដេចដែលហៅថា គុណនាម? គុណនាមមានប៉ុន្មាន? គឺអ្វីខ្លះ? ចូរាប់ហើយឲ្យអត្ថន័យមួយ ៗ?

ការហាត់

៦៤- គុណនាមទាំងនោះ មានពាក្យអ្វីជាសំគាល់ ដើម្បីឲ្យឃើញថាប្លែកគ្នា? តើពាក្យនោះនៅខាងមុខ ឬខាងដើម ?

៦៥- ចូរធ្វើបកតិគុណនាមខាងក្រោមនេះ ឲ្យទៅជាវិសេសគុណនាម ជាអតិវិសេសគុណនាម ៖

ស, ខ្មៅ, សម្បុរស, សភាព, ស្អុត, ត្រង់, វៀច, គោង, កាច, សាហាវ, យង់យ្ងង ។

អត្ថបទ ក្អែកញីឈ្មោលនិងពស់

មានក្អែកញីឈ្មោលមួយគូ សម្បុរខ្មៅរលើមយង់ អាស្រ័យនៅលើដើមឈើមួយដើមធំ មូលគ្រឈងគ្រង់ឈ ។ ក្នុងព្រង់ដើមឈើនោះ មានពស់វែកមួយ ។ ពស់នោះតែងចាប់កូនក្អែកតូចធំ ស៊ីជាអាហារ ។ ក្អែកញីនិយាយទៅប្ដីថា បងអើយយើងនៅនេះមិនបានសុខទេ ព្រោះអាពស់

ចាស្រែងឃោរឃៅចេះតែស៊ីកូនយើងយ៉ាងនេះ មើលទៅយើងអស់ពូជពង្សទៀតហើយ ។ ក្អែកឈ្មោលថា នែប្អូនសំឡាញ់! កុំថប់អ៊ូទុកឲ្យបង ។ ក្អែកញីថា ចុះបើពស់នេះមានពិសខ្លាំងច្រើនជាងយើង តើយើងគិតធ្វើដូចម្ដេច? ប្អូនកុំឆ្ងល់អ្វី មិនមើលសត្វសីហៈ ម៉េចទន្សាយសម្លាប់បានៗ ក្អែកញីអស់សំណើចនៅស្ងៀម ។

សំនួរ

៦៦. ចូរស្រង់យកគុណនាម នៅក្នុងអត្ថបទនេះ? ហើយធ្វើបកតិគុណនាមឲ្យទៅជាអតិវិសេសគុណនាម ទាំងអស់?

៦៧– ចូរសម្ពន្ធនាមនឹង គុណនាម ក្នុងប្រយោគ

« ពស់នោះតែងចាប់កូនក្អែកតូចធំ ស៊ីជាអាហារ »

៦៨– អក្ខរាវិរុទ្ធ

ពូជ (ប្រភពជ) ។ ពង្ស <វ > ព > ពង្ស ។

៦៩- សរសេរតាមសូត្រ ក្អែកញី ឈ្មោលទឹងពស់

៧០- តែងសេចក្តី

ចូរអ្នកអធិប្បាយអំពីបក្សីណាមួយ ដែលអ្នកបានឃើញដោយមានអាសន្នមកដល់ ។ មេបាការពារកូន តើអ្នកមានចាប់អារម្មណ៍ដូចម្តេចខ្លះទៅលើសត្វទាំងនោះ ។

---

## មេរៀនទី១០

# កិរិយាសព្ទ



អ្នកគង្វាល វាយ គោ ឥតត្រាប្រណី ហើយចង បង្អត់ មិនឲ្យស៊ីស្មៅ

### ពិនិត្យ

ពាក្យថា វាយ ជាសព្ទសំរាប់បញ្ជាក់ឲ្យឃើញថា តើអ្នកគង្វាលនេះ ធ្វើអ្វី មានភាពដូចម្ដេច ? កិច្ចដែល អ្នកគង្វាលត្រូវធ្វើ ជាតួអំពើ ដូចជាពាក្យថា វាយនេះ ជា កិច្ចដែលអ្នកគង្វាលត្រូវធ្វើ ហៅថា កិរិយាសព្ទ

## សម្ពន្ធ

ភាយ | កិរិយាស័ព្ទ ឯកវចនៈ មានអ្នកគង្វាល

ជាប្រធាន

បំណាំ : របៀបសម្ពន្ធ កិរិយាស័ព្ទ ត្រូវមានវចនៈ

ទៅតាមបទប្រធាន ។

## មេរៀន

កិរិយាស័ព្ទ គឺជាសព្ទ ដែលសម្រាប់បញ្ជាក់ថា

កិច្ចដែលត្រូវធ្វើ ។

ឧ - ខ្ញុំដើរ

កិរិយាស័ព្ទមានពីរយ៉ាងគឺ សកម្មកិរិយា និងអកម្ម

កិរិយា ។

វេយ្យាករណ៍ ពាក្យស័ព្ទ

- សំនួរ

៧១- កិរិយាស័ព្ទមានន័យដូចម្ដេច ? មានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ? ចូរគេកិរិយាស័ព្ទដែលប្រើក្នុងការសិក្សា?

ការហាត់

៧២. ចូរតែងឃ្លាជាមួយកិរិយាខាងក្រោមនេះ

ស្វាធ្យាយ, សំដែង, សូត្រ ថ្លែង, តែង, ប្រកាស, ឃោស្នា, អាក្រោស, អំពាវនាវ,

អត្ថបទ ត្រីមួយត្រកួនមួយស្មុគស្មាញទាំងអស់

មានកសិករម្នាក់ឈ្មោះសុមន្ទ បានចិញ្ចឹមពានរមួយ ៗ ថ្ងៃមួយ គាត់ទៅស្រែយកស្វា ពពៃទៅជាមួយគ្នា ដល់ពេលឃ្លានបាយ ក៏ចុះទៅខ្ទុរមាត់ក្នុងស្រះ ហើយទុកអាហារនៅក្បែរគល់ឈើ ៗ

លំដាប់នោះស្វាវិលខួច ស៊ីអាហារអស់គ្មានសល់ ៗ ទធិដែលនៅជាប់នឹងដៃវា ក៏យកទៅលាបប្រឡាក់មាត់ពពែដែលឈរនៅជិតនោះ ហើយមកឈរធ្វើពុកព្រងើយដូចជាមិនដឹងមិនឮសោះ ៗ

កសិករត្រឡប់មកវិញបាយអស់រលីង ពិនិត្យមើលទៅឃើញមាត់ពពែប្រឡាក់សុទ្ធតែទធិ ៗ អ្នកស្រែឆោតល្ងង់មិនបានពិចារណា ចាប់ដំបងវាយសំពងពពែស្លាប់ ៗ

មនុស្សអសប្បុរសតែងធ្វើខុសខ្លួនឯង ហើយទំលាក់កំហុសនោះ ទៅលើសប្បុរសដែលឥតកំហុស ព្រោះហេតុនោះហើយមនុស្សឆោតល្ងង់គ្មានការពិសោធន៍ ពិចារណារកខុសត្រូវ ធ្វើតាមតែអំពើចិត្ត ៗ

ព្រោះហេតុនោះហើយ បានជាបណ្ឌិតពោលថា "មនុស្សល្ងង់ធ្វើអំពើអាក្រក់ឯណា អំពើអាក្រក់នោះ រមែងឲ្យទុក្ខ

ដល់សប្បុរសមិនខាន" ដូចស្វាស៊ីអាហារផ្លែត ពពៃស៊ីដំបង់ដំនួសពានរ ៗ "ផ្លែតពោះស្វា" "ទ្រមមាគិតាពពៃ" ៗ

សំនួរ

៧៣–ចូរគូសបន្ទាត់ក្រោមកិរិយាស័ព្ទ ដែលមាននៅក្នុងអត្ថបទនេះ ? ចូររកសទិសស័ព្ទនឹងពាក្យថាពោះ ? ហើយពន្យល់ន័យមួយ ៗ ? ចូរសម្ពន្ធស័ព្ទក្នុងប្រយោគទី១ ?

ការហាត់

៧៤–អ្នកយល់ឃើញដូចម្ដេច ចំពោះសត្វស្វា ? ចាត់ជាសត្វពាលបានឬទេ ? ចូរស្រង់យកពាក្យដែលបង្អុលឲ្យឃើញថាជាសត្វពាល ?

៧៥ –ចូរពន្យល់ស័ព្ទខាងក្រោមនេះខ្លះ (តាមក្រិត,កត្តានុរូប - អត្ថបដិរូប - វេវចនៈ)

កសិករ, អ្នកស្រែ, ពានរ, ស្វា, ផាយ, អាហារ,

កំហុស, ខុស, ស្វាស៊ីអាហារ, ពពែស៊ីដំបង ។

៧៦- អក្ខរាវិរុទ្ធ

ឈរ(រ) ។ ស្មើរ(រ) ។ ពានរ (រ) ។ ពិសោធន៍ (ន៍) ស័ព្ទនេះជានាម បើកិរិយាវិញ ត្រូវសរសេរជា ពិសោធ

៧៧–សរសេរតាមក្បួន ត្រីមួយត្រកស្អុយមួយ ស្អុយទាំងអស់

៧៨– តែងសេចក្តី

ក្មេងម្នាក់នៅក្នុងថ្នាក់ដែលមានកំហុសតែគ្មានអ្នកណាដឹងសោះ ហើយកំហុសនោះធ្លាក់មកលើកូនសិស្សទាំងអស់ក្នុងថ្នាក់ ហើយអ្នកបានឃើញ ។

ចូរអ្នកអធិប្បាយអំពីបុគ្គល សំដីដែលវាឆ្លើយដាក់ទៅគេឯទៀត ហើយទឹកចិត្តអ្នក ដែលត្រូវជំរាបលោកគ្រូដូចម្តេចឲ្យលោកគ្រូចូលចិត្តផង ។

# មេរៀនទី ១១

## កិរិយាស័ព្ទ (ត)

| អកម្មកិរិយា | សកម្មកិរិយា |
| --- | --- |
| (មិនមានអំពើ) | (មានអំពើទើបគ្រប់គ្រាន់) |






១ អ្នកអត្តពល រត់ យ៉ាងលឿន

២ អ្នកអត្តពល ទាត់បាល់

## ពិនិត្យ

១–អ្នកអត្តពល រត់ ពាក្យថា រត់ នេះមិនបាច់មានបទកម្មមកទេ ក៏អាចសំរេចអំពើខ្លួនឯងបាន ។ កិរិយាស័ព្ទ

បែបនេះតាំងអស់មិនត្រូវមានបទកម្មជាដកប ដូចជាដើរ យំ សើច... ហៅថាអកម្មកិរិយា

២ ពាក្យថាទាត់ កិរិយាស័ព្ទបែបនេះគឺត្រូវតែមានបទកម្មជាដកបដែលជាកម្មរងរបស់កិរិយានោះ ឧបមាបើនិយាយតែកិរិយាទទេ ៗ គេស្តាប់មិនបានជាដាច់ខាតដូចជាគេថាទាត់ បើមិនដាក់កម្មរងមកទេ មិនដឹងថាទាត់អ្វី ៗ វាយមិនដឹងជាវាយអ្វី កិរិយាស័ព្ទបែបនេះហៅជាសកម្មកិរិយា

## សង្ខេប

| | |
|---|---|
| រត់ | អកម្មកិរិយា ឯកវចនៈ មានអត្តពលជាប្រធាន |
| ទាត់ | សកម្មកិរិយា ឯកវចនៈ មានអត្តពលជាប្រធាន |

ចំណាំ មុននឹងសម្ពន្ធកិរិយាស័ព្ទត្រូវគេមើលបទប្រធានសិន បើប្រធានជាឯកវចនៈ ត្រូវសម្ពន្ធកិរិយាស័ព្ទជាឯកវចនៈបើជាពហុវចនៈ ត្រូវសម្ពន្ធជាពហុវចនៈ

## មេរៀន

១ អកម្មកិរិយា គឺកិរិយាស័ព្ទណា ដែលប្រើបាន មិនបាច់មានបទកម្ម (ជាកិរិយាស័ព្ទមានបទកម្មពេញគ្រប់គ្រាន់)

ឧ ក្នុងវេលានោះ គីង្គក់ណោតបុះលោតឡើង . . .

(ស្រង់ពីសំរាំង)

២ សកម្មកិរិយា កិរិយាស័ព្ទណាដែលមានបទកម្មមកចូលសំរេចអំពើទើបបានគ្រប់គ្រាន់

ឧ អ្នកអត្តពលទាត់ បាល់

វេយ្យាករណ៍ វាក្យស័ព្ទ

សំនួរ

៧៩. សកម្មកិរិយា នឹងអកម្មកិរិយាប្លែកគ្នាដូចម្តេច? ចូរលើកឧទាហរណ៍ អំពីកិរិយាស័ព្ទទាំងពីរបែបនេះ ?

ការហាត់

៨០. ចូរគូសបន្ទាត់មួយ ក្រោមកិរិយាស័ព្ទជា

សកម្មកិរិយា គូសខ្វែងជើងក្អែកក្រោមអកម្មកិរិយា

ត្រីក្រាញ់ប្រមៀលឡើងគោក ៗ កូនក្អែងចាប់ត្រីនោះ ៗ ពេលល្ងាច ក្អែងគៀងគោចូលក្រោល ៗ គោខ្លះបោលលោតរត់យ៉ាងសប្បាយ ៗ ក្អែងចង់គោមិនឲ្យស៊ីស្មៅ ៗ

## អត្ថបទ ទន្សាយជាប់អន្ទាក់

ឯទន្សាយ លុះដល់ប្រលប់យប់ងងឹតគិតចង់ស៊ីស្រូវសំណាបក៏ស្ទុះលោតចូលទៅស៊ីទាល់តែឆ្អែត ៗ លុះដល់ព្រឹកម្ចាស់សំណាប មកឃើញស្នាមទន្សាយស៊ីសំណាប ដូច្នេះ ខឹងណាស់ក៏ធ្វើអន្ទាក់ដាក់យកទន្សាយ ៗ ទន្សាយញ៉ាមមិនបានគិត ក៏មកជាប់អន្ទាក់មែនហើយក៏ធ្វើពុតជាស្លាប់ដេកស្តូក ៗ ម្ចាស់សំណាប មកឃើញទន្សាយអរណាស់ ដោះទន្សាយដាក់ក្បែរខ្លួន រៀបដាក់អន្ទាក់ទៅវិញទន្សាយបោលប្រែបលោតផ្លោះរត់ចូលទៅព្រៃវិញ ៗ